## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៥៦៣/២៦-៧-២០០៦
សាលដីកា
លេខ : ១៤៧ "ជ"/០១-៩-២០០៥

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើ តាមក្រឹត្យ លេខ ០៦ក្រ ចុះថ្ងៃទី ០៩ កុម្ភៈ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ កាលពីថ្ងៃទី ០១-៩-២០០៥ ដែលមានសមាសភាពដូចខាងក្រោមនេះ

**ក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រម

លោក [redacted] ជាចៅក្រម

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

លោកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ : ៥៦៣ ចុះថ្ងៃទី ២៦-៧-២០០៦ រវាង :

- ជនជាប់ចោទឈ្មោះ [redacted] សុខា " ចុងបណ្តឹងឧទ្ធរណ៍ " ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ នៅភូមិវា[redacted]ពោធិ៍សាត់។ ឪពុកឈ្មោះ [redacted] គុណ " រ " ម្តាយឈ្មោះ [redacted] ស" នៅលីវ ។

ត្រូវចោទពីបទ : **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តិនៅ ភូមិវាលវង់ ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ១២ ខែមេសា ឆ្នាំ២០០៥ តាមមាត្រា ០៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

- ចាប់ខ្លួននៅថ្ងៃទី ១២-៤-២០០៥ . - ឃុំខ្លួន នៅថ្ងៃទី ១៣-៤-២០០៥ ។
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់នី អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ រស់នៅភូមិវាលវង់ ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។
- ជនរងគ្រោះឈ្មោះ [redacted] សុផា " ដើមបណ្តឹងឧទ្ធរណ៍ " ភេទស្រី អាយុ ៥ឆ្នាំ ។

**អង្គហេតុមានដូចតទៅ :**

តាមពាក្យបណ្តឹងចុះថ្ងៃទី ២២-៤-២០០៥ របស់ ឈ្មោះ[redacted] ចាន់នី បានប្តឹងពី ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ២៥ឆ្នាំ ដែលបានចាប់កូនស្រីខ្លួន ឈ្មោះ [redacted] សុផា អាយុ ៥ឆ្នាំ រំលោភសេពសន្ថវៈ រហូតបានសំរេច

បំណងរបស់វា ក្នុងពេលដែលកូនស្រីខ្លួន ដើរត្រលប់មកពីទិញស្រាឱ្យពូរបស់វា បានពាក់កណ្ដាលផ្លូវ ។ ហើយឈ្មោះនេះ បានចាប់ រំលោភកូនស្រីខ្លួនចំនួន ៣ដងមកហើយ តែខ្លួនមិនបានដឹង ព្រោះឈ្មោះនេះគំរាមកូនខ្លួនមិនឱ្យប្រាប់គេ បើគេដឹង វា នឹងសំលាប់ចោល ទើបតែលើកនេះ កូនខ្លួនបានប្រាប់ខ្លួន ។

**- បានឃើញសាលក្រមព្រហ្មទណ្ឌ លេខ ៖ ៥៥ ចុះថ្ងៃទី ២២-២-២០០៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានខ្លឹមសារដូចតទៅ ៖**

១- ផ្ដន្ទាទោសឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារតំរូវឱ្យធ្វើការកំណត់ ១០ឆ្នាំ (ដប់ឆ្នាំ) គិតពី ថ្ងៃឃុំខ្លួន ។

ពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈប្រព្រឹត្តិនៅ ភូមិវាលវង់ ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៥ ។ តាមមាត្រា ០៥ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

២- ឱ្យជនជាប់ចោទឈ្មោះ[redacted] សុខា សងសំណងជម្ងឺចិត្ត ឱ្យទៅ ឈ្មោ[redacted] ចាន់នី តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី តំណាងឱ្យជនរងគ្រោះជាកូន ឈ្មោះ [redacted] សុផា ជាប្រាក់រៀលចំនួន ៤.០០០.០០០៛ (បួនលានរៀល)។ សំណើរសុំលើសពីនេះ បដិសេធចោល ។

ករណីទណ្ឌិតខាងលើ គ្មានប្រាក់សង ត្រូវដាក់គុកបង្ខំរូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ដើម្បីធានាប្រាក់ធនទណ្ឌ តាមច្បាប់ ស្ដីពីការដាក់គុកបង្ខំរូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើ តាម ក្រឹត្យលេខ ១៨ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

៣- សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវប្ដឹងឧទ្ធរណ៍កំណត់ច្បាប់ ។

សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] ចន្ទ័សុខា មេធាវី ឱ្យជនរងគ្រោះ ប្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២-០២-២០០៦ ត្រង់ចំណុចទី ១ នៃសាលក្រម ។

- បានឃើញសេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ១០-៥-២០០៧ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ។
- បានឃើញរបាយការណ៍ ចុះថ្ងៃទី ២៥-៦-២០០៥ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

- ជនជាប់ចោទ ឈ្មោះ [redacted] សុខា "អវត្តមាន"
- ដើមបណ្ដឹង ឈ្មោះ [redacted] ចាន់នី " វត្តមាន "
- មេធាវីការពារជនជាប់ចោទ ឈ្មោះ [redacted] សុខា " វត្តមាន "
- ជនរងគ្រោះ ឈ្មោះ [redacted] សុផា " វត្តមាន "
- ប្រធានក្រុមប្រឹក្សា ធ្វើការអធិប្បាយហេតុការណ៍ នៃរឿងដែលកើតមានឡើង និងអានសេចក្ដីសំរេច របស់សាលាដំបូងខេត្តពោធិ៍សាត់ ។
- ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ចាន់នី បានឆ្លើយថា ៖ ក្នុងរឿងនេះ ខ្ញុំសុំឱ្យតុលាការសាលាឧទ្ធរណ៍ ដាក់គុកជនល្មើស ឈ្មោះ [redacted] សុខា ឱ្យធ្ងន់ធ្ងរ ។
- **តំណាងមហាអយ្យការសន្និដ្ឋាន** ៖ សេចក្ដីសុំប្ដឹងតវ៉ារបស់មេធាវីឈ្មោះ [redacted] ចន្ទ័សុខា ធ្វើឡើងក្នុងកំណត់ច្បាប់ ។ មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ២៥ឆ្នាំ ពីបទ ៖

[illegible]សេពសន្ថវៈ កាលពីថ្ងៃទី ១២-៤-០៥ ។ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ តាមកោសល្យវិច្ច័យលេខ ០៣៧ / ១ /០៦ អ ព.ព ស ចុះថ្ងៃទី ៣០-១-២០០៦ របស់មន្ទីរពេទ្យខេត្តពោធិ៍សាត់ ឃើញមាន : - ស្នាមដាច់សន្ទះព្រហ្មចារីយ ត្រង់ចំណុចលេខ ៧ ។

- មាត់ព្រហ្មចារីយរីកធំខុសធម្មតា ។

យល់ឃើញថា : សំអាងហេតុនៃសេចក្តីសំរេច នៃសាលក្រមលេខ ៩៥ ចុះថ្ងៃទី ២២-២-២០០៦ របស់តុលាការខេត្តពោធិ៍សាត់ មានលក្ខណៈត្រឹមត្រូវ ។ ហេតុនេះ សូមតំកល់សាលក្រមលេខ : ៩៥ ចុះថ្ងៃទី ២២-២-២០០៦ ទុកជាបានាការ ។

- **មេធាវីធ្វើ លោក[redacted] សុខា ការពារឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋាន** : សូមប្រធានក្រុមប្រឹក្សាសំរេចតាមច្បាប់ចុះ ។

- ក្រោយពីបានអាន ចម្លើយជនជាប់ចោទ ។
- ក្រោយពីបានអាន និងស្តាប់ចម្លើយដើមបណ្តឹង ។
- ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។
- ក្រោយពីបានស្តាប់មេធាវីធ្វើសេចក្តីសន្និដ្ឋាន ។
- ក្រោយពីបានពិនិត្យឯកសារពាក់ពន្ធ័ល្អិតល្អន់ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

**សាលាឧទ្ធរណ៍**

- យល់ឃើញថា :

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃ ២២ កុម្ភៈ ២០០៦ របស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៦០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ ទទួលជំនុំជំរះបាន ។

២- មេធាវី[redacted] **សុខា** ជាមេធាវីការពារក្តីឱ្យជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣- មេធាវីតំណាងឱ្យដើមបណ្តឹង ប្តឹងពីចំណុចផ្តន្ទាទោស លើជនជាប់ចោទ ដែលតាមមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាព តែលើសំណងរដ្ឋប្បវេណី ប៉ុណ្ណោះ ។ ដូចនេះ សាលាឧទ្ធរណ៍មិនលើកយកមកពិចារណាឡើយ ។

៤- សាលក្រមព្រហ្មទណ្ឌ លេខ ៩៥ ចុះថ្ងៃ ២២ កុម្ភៈ ២០០៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ មានលក្ខណៈត្រឹមត្រូវគួរតម្កល់ទុកជាបានការ ។

**ហេតុដូចនេះទីនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃ ២២ កុម្ភៈ ២០០៦ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[redacted] ធានី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ៩៥ ចុះថ្ងៃ ២២ កុម្ភៈ ២០០៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ទុកជាបានការ ។

-លុបចោលវិធានអនុវត្តដាក់គុកបង្ខំរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ ចេញពីសេចក្តីប្រកាសនៃសាលក្រមតាមមាត្រា ៥២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ ក៏ដូចជាមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មក មន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែងដែលត្រូវប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើបានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជំរះ

ហត្ថលេខា [redacted] ហត្ថលេខា [redacted] , [redacted] ហត្ថលេខា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី..... ខែ..... ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

[redacted]